# ការបន្សុទ្ធពូជស្រូវ





នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម

លេខ : ២ ឆ្នាំ ២០០២

ពូជស្រូវសុទ្ធល្អ ជាមូលដ្ឋានគ្រឹះក្នុងការផលិតពូជស្រូវ ព្រោះគ្រាប់ពូជសុទ្ធល្អមានគុណភាពខ្ពស់ ជាកត្តាធ្វើអោយការបង្កបង្កើនផលស្រូវរបស់គាត់ទទួលបាននូវទិន្នផលខ្ពស់ និងមានតំលៃថ្លៃជាងពូជស្រូវដែលមិនសុទ្ធ ហើយអាចនាំទៅលក់នៅទីផ្សារអន្តរជាតិថែមទៀតផង ។ ប្រជាកសិករយើងនឹងទទួលប្រាក់ចំណូលសំរាប់សេដ្ឋកិច្ចគ្រួសារ ។ ដូចនេះកសិករយើងគប្បីស្វែងយល់ នឹងយកចិត្តទុកដាក់អំពីរបៀបផលិតពូជសុទ្ធល្អ នឹងធ្វើការថែទាំឱ្យបានហ្មត់ចត់ ។

## ១- ការរៀបចំដី :

ការរៀបចំដីសំរាប់ធ្វើថ្នាលសំណាបយើងត្រូវធ្វើយ៉ាងណាឱ្យនៅឆ្ងាយពីពូជផ្សេងៗទៀត ។ ម្យ៉ាងទៀតការរៀបចំដីស្ទូងវិញ ត្រូវភ្ជួររាស់អោយបានច្រើនដង ក្នុងមួយដងៗ មានរយៈពេល ៧ ទៅ ១៥ ថ្ងៃ ដើម្បីឱ្យស្មៅ និងពូជផ្សេងៗទៀតដុះ រួចភ្ជួររាស់ជាលើកចុងក្រោយទើបពង្រាបដីអោយបានស្មើល្អ ។

## ២- ការជ្រើសរើសគ្រាប់ពូជ :

គ្រាប់ពូជដែលល្អត្រូវមានលក្ខណៈដូចខាង

ក្រោម ៖

- គ្រាប់ពូជដែលសុទ្ធល្អ មិនលាយឡំពូជផ្សេងៗ ឬគ្រាប់ស្មៅ ។
- ពូជដែលផ្តល់ទិន្នផលខ្ពស់រយៈពេលលូតលាស់ខ្លី
- មានប្រភពច្បាស់លាស់
- គ្រាប់ពូជត្រូវមានទំហំគ្រាប់ប៉ុនៗគ្នា ពណ៌ដូចគ្នា ហើយមានដំណុះពី ៩០ % ឡើងទៅ ។
- គុណភាពអង្ករល្អមានតំលៃខ្ពស់លើទីផ្សារ ។

### ៣_ ការសំអាតឧបករណ៍នៅពេលត្រាំគ្រាប់ពូជ ៖

ជាដំបូងនៅមុនពេលត្រាំគ្រាប់ពូជ អ្នកត្រូវសំអាតឧបករណ៍ដូចជា ៖ ពាង, ធុង , បាវ, ការ៉ុង ដែលត្រូវត្រាំគ្រាប់ពូជនោះអោយបានស្អាតល្អ ជៀសវាងមានគ្រាប់ពូជផ្សេងៗទៀត នៅជាប់នឹងឧបករណ៍នោះ ។

### ៤_ ការបន្សុទ្ធពូជនៅពេលស្រូវកំពុងដុះលូតលាស់ ៖

នៅដំណាក់កាលស្រូវកំពុងលូតលាស់ ការបន្សុទ្ធពូជនេះ វាមានសារៈសំខាន់ណាស់ ព្រោះយើងអាចពិនិត្យឃើញពីលក្ខណៈខុសគ្នា នៃការដុះលូតលាស់របស់ស្រូវ ។ ពេលវេលាដែលត្រូវធ្វើការបន្សុទ្ធនៅក្នុងដំណាក់កាលចេញកួរ ពីព្រោះថ្ងៃខែនៃការចេញកួរនេះ អាចកំណត់បានពីពូជដែលមានអាយុកាលខ្លី និងដែលមានអាយុកាលវែង ។ ការបន្សុទ្ធពូជដោយសំរិតសំរាំងនេះ អាចធ្វើទៅបាននៅគ្រប់ដំណាក់កាលរបស់ដំណាំស្រូវដែលមានលក្ខណៈខុសគ្នាដូចជា ៖ កំពស់ , ពណ៌ដើម , ដើម , ពណ៌ស្លឹក និងពណ៌គ្រាប់ , កំណកំណើតកួរ ថ្ងៃចេញផ្កា , ទំហំស្លឹក , ទំហំគ្រាប់ , ការដុះកន្ទុយរបស់គ្រាប់ស្រូវ ។ល។

ប្រសិនបើយើងពិនិត្យឃើញថា ដើមណាដែលមានលក្ខណៈខុសប្លែកពីពូជដែលអ្នកចង់បាន ត្រូវដកចេញឬកាត់ចោលតែម្តង ដើម្បីជៀសវាងមានពូជលាយឡំគ្នា ។

### ៥_ ការបន្សុទ្ធពូជនៅពេលច្រូតកាត់បោកបែន ៖

ដើម្បីជៀសវាងកុំអោយមានពូជផ្សេងៗនៅជាប់នឹងឧបករណ៍ដែលទុកសំរាប់ធ្វើការបោកបែន នៅពេលច្រូតកាត់ ចាំបាច់ត្រូវសំអាតឧបករណ៍ទាំងនោះអោយបានស្អាតជាមុនសិន រួចហាលឱ្យ

ស្ងួត ។ ម្យ៉ាងទៀតការច្រូតកាត់ត្រូវធ្វើនៅពេលស្រូវទុំស្រុស កុំទុកឱ្យទុំខ្លាំងពេក ការបោកបែននេះគឺត្រូវធ្វើដោយឡែកពីស្រូវបរិភោគ ។ ក្នុងករណីធ្វើការបោកបែនពូជស្រូវនេះ មិនត្រូវបោកខ្លាំងពេកទេ ព្រោះបណ្តាលឱ្យគ្រាប់ពូជស្រូវបាក់ស្រាំនាំឱ្យដំណុះទាប ។

## ៦. ការបន្សុទ្ធពូជនៅពេលទុកដាក់ពូជ :

យើងត្រូវសំអាតឧបករណ៍ និងទីកន្លែងទុកដាក់ឱ្យបានស្អាត ហើយទុកអោយឆ្ងាយពីស្រូវបរិភោគ ដើម្បីជៀសវាងការឆ្លងពូជដោយសារជាប់នឹងឧបករណ៍ប្រើប្រាស់ ឬក៏ដោយសត្វផ្សេងៗទៀតដូចជា កណ្តុរ មាន់ជាដើម ។


រៀបរៀងដោយ

ភ្នាក់ងារប្រតិបត្តិទី២ (ការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម)

នៃគំរោងឥណទានកម្មវិធី របស់ធនាគារអភិវឌ្ឍន៍អាស៊ី

ADB, Loan No. 1445 CAM (SF)

អាសយដ្ឋាន : លេខ ២០០ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ